# សុន្ទរកថា

# របស់

# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# និង ជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

# ថ្លែងក្នុង

# ពិធីសម្ពោធដាក់ឱ្យដំណើរការ

# «គម្រោងសហហិរញ្ញប្បទានស្តារវិស័យទេសចរណ៍»

តាមប្រព័ន្ធវីដេអូ, ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០២២

- *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*
- *សមាជិក-សមាជិកាទាំងអស់ នៃអង្គពិធី, ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំមានកិត្តិយស និង សេចក្តីសោមនស្សក្រៃលែង ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការ **«គម្រោងសហហិរញ្ញប្បទានស្តារវិស័យទេសចរណ៍»** ក្នុងកញ្ចប់ថវិកា ចំនួន ១៥០ លានដុល្លារអាម៉េរិក ដែលជាបដិភាគរវាងរាជរដ្ឋាភិបាល និង គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) ។ ខ្ញុំសូមជម្រាបជូនថា គម្រោងសហហិរញ្ញប្បទាននេះ គឺជាផ្នែកមួយនៃការគាំទ្រដល់ការអនុវត្ត **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣»** ដែលរាជរដ្ឋាភិបាលបានអនុម័ត និង ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២១ កន្លងទៅ ។

ដូចដែល **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី** បានជ្រាបហើយថា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ, ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** វិស័យទេសចរណ៍កម្ពុជាបានលូតលាស់គួរឱ្យកត់សម្គាល់ និង បានបំពេញតួនាទីជាសសរស្តម្ភមួយយ៉ាងសំខាន់ សម្រាប់សេដ្ឋកិច្ចកម្ពុជា ។ ជាក់ស្តែង, នៅក្នុងឆ្នាំ ២០១៩, មុនការមកដល់នូវវិបត្តិនៃជំងឺកូវីដ-១៩, វិស័យទេសចរណ៍បានផ្តល់នូវចំណូលដុលដែលទទួលបានពីភ្ញៀវទេសចរណ៍អន្តរជាតិ ក្នុងទំហំទឹកប្រាក់ប្រមាណ ៤.៩១៩ លានដុល្លារអាម៉េរិក ដល់សេដ្ឋកិច្ចកម្ពុជា និង បានរួមចំណែកប្រមាណ ៤,៤% នៃ ផសស ។ ជាអកុសល, ដូចដែលបានគូសបញ្ជាក់ដោយ **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍**, ក្នុងអំឡុងឆ្នាំ ២០២០ និង ឆ្នាំ ២០២១, វិស័យទេសចរណ៍បានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារឥទ្ធិពលនៃជំងឺកូវីដ-១៩ និង បានបណ្តាលឱ្យសហគ្រាសជាច្រើននៅក្នុងវិស័យនេះ កាត់បន្ថយ, ផ្អាក ឬ បិទអាជីវកម្មទាំងស្រុងតែម្តង ដែលជាហេតុនាំឱ្យប្រជាពលរដ្ឋរាប់ម៉ឺននាក់ បានបាត់បង់ការងារ និង ប្រាក់ចំណូល ។

ក្នុងទិសដៅគាំទ្រ, ជំរុញ និង ស្តារវិស័យទេសចរណ៍ឡើងវិញ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ជាច្រើន មានជាអាទិ៍៖ (១)-ការបើកប្រាក់ឧបត្ថម្ភជូនកម្មករ-និយោជិតក្នុងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរការងារដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ដោយម្នាក់ៗទទួលប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាម៉េរិក ក្នុងមួយខែពីរាជរដ្ឋាភិបាល; (២)-ការមិនយកកម្រៃសេវាលើការផ្តល់អាជ្ញាបណ្ណ និង លិខិតអនុញ្ញាតពាក់ព័ន្ធការសុំបើកឡើងវិញ ដូចជា ប៉ាតង់សណ្ឋាគារ និង ភោជនីយដ្ឋាន ជាដើម; (៣)-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ទេសចរណ៍ដែលមានស្រាប់ ឬ ទើបបង្កើតថ្មី; (៤)-ការផ្តល់ការបណ្តុះបណ្តាលជំនាញថ្មីដល់កម្មករ-នយោជិតដែលបាត់បង់ការងារ; (៥)-ការអនុវត្តកម្មវិធីសហហិរញ្ញប្បទាន; និង (៦)-ការជំរុញទីផ្សារទេសចរណ៍ តាមរយៈយុទ្ធនាការផ្សព្វផ្សាយ សំដៅបង្កើនទំនុកចិត្តលើកម្ពុជា ជាគោលដៅសុវត្ថិភាព, និង ការអភិវឌ្ឍផលិតផលទេសចរណ៍ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្តថ្មីៗ ។ល។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ឱ្យអនុវត្ត នូវ **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥** និង **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥**, និង គ្រោងដាក់ឱ្យអនុវត្តជាផ្លូវការ នូវ **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ២០២២-២០៣៥** នាពេលឆាប់ៗខាងមុខនេះ ផងដែរ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ខណៈដែលវិបត្តិនៃជំងឺកូវីដ-១៩ កំពុងថមថយ, វិស័យទេសចរណ៍ចាប់ផ្តើមមានសម្ទុះងើបឡើងវិញជាសកល ដោយប្រទេសភាគច្រើនបានបន្ធូរបន្ថយ នូវវិធានការរឹតបន្តឹងពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ និង បានលើកលែង ឬ ដកចេញនូវលក្ខខណ្ឌតម្រូវជាច្រើន សម្រាប់ការធ្វើដំណើរអន្តរជាតិ ។ ផ្អែកតាមការព្យាករណ៍របស់អង្គការទេសចរណ៍ពិភពលោក (WTO), វិស័យទេសចរណ៍សកលនឹងត្រលប់ទៅរកគន្លងកំណើន ដូចពេលមុនវិបត្តិនៃជំងឺកូវីដ-១៩ នៅឆ្នាំ ២០២៤ ខាងមុខ ។ ក្នុងន័យនេះ, ជាមួយនឹងកិច្ចអន្តរាគមន៍ដ៏សកម្មរបស់រាជរដ្ឋាភិបាល, វិស័យទេសចរណ៍កម្ពុជា ត្រូវបានព្យាករថា នឹងមានកំណើនប្រមាណ ១៦% ក្នុងឆ្នាំ ២០២២, និង ២៣% ក្នុងឆ្នាំ ២០២៣ ។ ការងើបឡើងនៃវិស័យទេសចរណ៍ ក៏ដូចជាសេដ្ឋកិច្ចទាំងមូល គឺជាលទ្ធផលនៃការដឹកនាំប្រកបដោយយុទ្ធសាស្ត្រច្បាស់លាស់ និង ចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមរយៈការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំង, ការដាក់ចេញនូវវិធានការសុខាភិបាល និង រដ្ឋបាល ព្រមទាំងវិធានការអន្តរាគមន៍ ទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព ដែលអនុញ្ញាតឱ្យមានការបើកដំណើរការទាំងស្រុងឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ច កាលពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១ រហូតមកដល់បច្ចុប្បន្ន ។

ទោះបីជាវិស័យទេសចរណ៍បានបង្ហាញនូវសញ្ញានៃការងើបឡើងវិញគួរឱ្យកត់សម្គាល់ក្តី, សហគ្រាសនៅក្នុងវិស័យនេះនៅបន្តជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ជាអាទិ៍៖ (១)-ការខ្វះសមត្ថភាពចាប់យកម៉ូដែលអាជីវកម្ម (business model) បែបឌីជីថល; (២)-ការស្ថិតនៅក្រៅប្រព័ន្ធរបស់សហគ្រាសភាគច្រើន; (៣)-ការខ្វះជំនាញបដិសណ្ឋារកិច្ចច្បាស់លាស់; និង (៤)-ការខ្វះទុន រួមទាំងទុនបង្វិល និង ទុនវិនិយោគ សម្រាប់រក្សាលំនឹង, កែលម្អ និង ពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។ សម្រាប់រាជរដ្ឋាភិបាល, ការស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះ គឺជាកត្តាចាំបាច់ដើម្បីគាំទ្រដល់វិស័យទេសចរណ៍កម្ពុជា ក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលនៃបរិយាកាសប្រកួតប្រជែងសកល ជាពិសេស ដើម្បីគាំទ្រដល់សហគ្រាសនៅក្នុងវិស័យទេសចរណ៍ ក្នុងការទាញយកផលប្រយោជន៍ជាអតិបរមាពីកាលានុវត្តភាពនានា ក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ទោះជាយ៉ាងណា, រាជរដ្ឋាភិបាលនៅតែចាត់ទុកវិស័យទេសចរណ៍ជាក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចដ៏សំខាន់មួយ ហើយប្តេជ្ញាគាំទ្រការស្តារ និង អភិវឌ្ឍវិស័យនេះឱ្យបានល្អជាងស្ថានភាពមុនវិបត្តិនៃជំងឺកូវីដ-១៩ ទៅទៀត ដើម្បីឱ្យវិស័យនេះក្លាយជាសសរស្តម្ភមួយនៃសេដ្ឋកិច្ចជាតិ ដែលនឹងចូលរួមវិភាគទានដ៏សំខាន់ ក្នុងការផ្តល់ការងារ និង ប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ។ ដើម្បីសម្រេចគោលដៅនេះ, ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសនៅក្នុងវិស័យទេសចរណ៍ គឺជាវិធានការចាំបាច់ណាស់ ដើម្បីជួយឱ្យសហគ្រាសទាំងនេះអាចស្តារ, ងើប និង ពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួនឡើងវិញ ព្រមទាំងចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការកែច្នៃវិស័យទេសចរណ៍ ឱ្យប្រកបដោយភាពទាក់ទាញកាន់តែខ្លាំងជាងមុន និង ជាពិសេស ប្រែក្លាយកម្ពុជាឱ្យទៅជាទិសដៅទេសចរណ៍ចម្បងមួយនៅក្នុងតំបន់ និង សកលលោក ។

ក្នុងន័យនេះ, ជាកិច្ចដំណើរការនៃការស្តារ និង ការជំរុញវិស័យទេសចរណ៍ឱ្យស្ទុះងើបឡើងវិញ ស្របតាម **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣»**, រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **«គម្រោងសហហិរញ្ញប្បទានស្តារវិស័យទេសចរណ៍»** ដើម្បីផ្តល់ហិរញ្ញប្បទានដល់សហគ្រាសនៅក្នុងវិស័យទេសចរណ៍សម្រាប់៖ (១)-ការបើកដំណើរការអាជីវកម្មឡើងវិញ; (២)-ការកែលម្អ និង ធ្វើទំនើបកម្មសេវាកម្មទេសចរណ៍; និង (៣)-ការពង្រីកខ្លួន និង ធ្វើពិពិធកម្មសេវាទេសចរណ៍ ដើម្បីត្រៀមទទួលភ្ញៀវទេសចរជាតិ និង អន្តរជាតិ នៅពេលដែលវិបត្តិនៃជំងឺកូវីដ-១៩ ថមថយទូទាំងសកលលោក ។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ជម្រាបជូនអង្គពិធីទាំងមូលថា **«គម្រោងសហហិរញ្ញប្បទានស្តារវិស័យទេសចរណ៍»** ដែលមានទំហំទឹកប្រាក់សរុបចំនួន ១៥០ លានដុល្លារអាម៉េរិកនេះ បានមកពីថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន ៧៥ លានដុល្លារអាម៉េរិក តាមរយៈធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា (SME Bank) និង ថវិកាបដិភាគរបស់គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) ចំនួន ៧៥ លានដុល្លារអាម៉េរិក ។ តាមរយៈគម្រោងនេះ, សហគ្រាសនៅក្នុងវិស័យទេសចរណ៍ដែលរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ អាចស្នើសុំឥណទានពីគ្រឹះស្ថានគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ដែលជាដៃគូរបស់ SME Bank ក្នុងអត្រាការប្រាក់សម្បទាន ។ ខ្ញុំសូមជម្រាបថា, កាលពីឆ្នាំ ២០២០ និង ឆ្នាំ ២០២១ កន្លងទៅ, តាមរយៈយន្តការ SME

Bank, រាជរដ្ឋាភិបាលក៏បានផ្ដួចផ្ដើម និង អនុវត្តកម្មវិធីសហហិរញ្ញប្បទាន ចំនួន ២ ជំហាន រួចមកហើយ ដោយជំហានទី ១ មានទឹកប្រាក់ចំនួន ១០០ លានដុល្លារអាម៉េរិក និង ជំហាន ទី ២ មានទឹកប្រាក់សរុប ២៤០ លានដុល្លារអាម៉េរិក ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និង មធ្យមក្នុងការរក្សាលំនឹងអាជីវកម្ម និង បង្កើតការងារថ្មី ក៏ដូចជាបង្កើនប្រាក់ចំណូលជូនប្រជា-ពលរដ្ឋ ក្នុងវិស័យអាទិភាព រួមទាំងវិស័យទេសចរណ៍ផងដែរ ដែលបានរងផលប៉ះពាល់ពីវិបត្តិ នៃជំងឺកូវីដ-១៩ ។ ដោយឡែក, ថវិកាទាំង ១៥០ លានដុល្លារអាម៉េរិក នៃ **«គម្រោងសហ-ហិរញ្ញប្បទានស្ដារវិស័យទេសចរណ៍»** ដែលនឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងពេលនេះ គឺផ្ដោតសំខាន់ សម្រាប់តែវិស័យទេសចរណ៍តែមួយប៉ុណ្ណោះ ដើម្បីពង្រឹងសក្ដានុពលនៃវិស័យទេសចរណ៍ បន្ថែមទៀត និង ចូលរួមសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យនេះ ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុឯកជនទាំងអស់ ដែលបានចូលរួមជាមួយ រាជរដ្ឋាភិបាលក្នុងការអនុវត្តកិច្ចការដ៏មានសារៈសំខាន់នេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី** ដែលជាតំណាងគ្រឹះស្ថានហិរញ្ញវត្ថុ ឯកជនទាំងអស់ នឹងបន្តសហការជាមួយរាជរដ្ឋាភិបាល ក្នុងការលើកស្ទួយការអភិវឌ្ឍវិស័យ ទេសចរណ៍ និង វិស័យអាទិភាពផ្សេងទៀតក្នុងកាលៈទេសៈដ៏លំបាកនេះ ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមគូសបញ្ជាក់ផងដែរថា អន្តរាគមន៍របស់រាជរដ្ឋាភិបាល តាមរយៈ ការបញ្ចេញកញ្ចប់ថវិកាទាំងនេះ គ្រាន់តែជាចំណែកតូចមួយក្នុងការបំពេញតម្រូវការហិរញ្ញ-ប្បទានដ៏ច្រើនសន្ធឹកសន្ធាប់របស់សហគ្រាស នៅក្នុងវិស័យទេសចរណ៍តែប៉ុណ្ណោះ ។ ដូច្នេះ, ការចូលរួមរបស់គ្រឹះស្ថានហិរញ្ញវត្ថុឯកជនក្នុងការផ្ដល់ឥណទានជូនសហគ្រាស នៅក្នុងវិស័យ នេះ ដោយប្រើប្រាស់ដើមទុនផ្ទាល់របស់គ្រឹះស្ថានខ្លួន ពិតជាមានសារៈសំខាន់ក្នុងការជួយ សម្រាលសម្ពាធ និង ចូលរួមគាំទ្រដល់សហគ្រាសទាំងនោះ ក្នុងការបើកដំណើរការអាជីវកម្ម ឡើងវិញ ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, អ្នកនាងកញ្ញា, ភ្ញៀវជាតិ និង អន្តរជាតិ និង អង្គពិធីទាំងមូល** បានប្រកបដោយ សុខភាពល្អបរិបូរណ៍, មានសុភមង្គលក្រុមគ្រួសារ, និង សម្រេចជោគជ័យ ក្នុងគ្រប់ភារកិច្ច ពិសេស ជៀសផុតពីជំងឺកូវីដ-១៩ ។

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **«គម្រោងសហហិរញ្ញប្បទានស្តារវិស័យទេសចរណ៍»** តាមរយៈ SME Bank ចាប់ពីពេលនេះតទៅ ។

***សូមអរគុណ!***